**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**'រ.ទ.ស.ភ'**

លេខ ២២៣ ស.ជ.ណ

ភ្នំពេញ, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៧

## លិខិតជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យា សាងសង់ដំបូលបន្ថែម និងដំបូលអគារនាយកដ្ឋានអាជីវកម្ម និងការជួសជុល កែសម្រួលបន្ទប់ដាក់ធុងក្ល័រ និងឃ្លាំងស្តុកអំបិល ដែលស្ថិតនៅរោងចក្រផលិតទឹកស្អាតជ្រោយចង្វារ

ខ្ញុំមានកិត្តិយសជម្រាបលោកស្រីប្រធានក្រុមហ៊ុន **អេស២ អេនជីនារីង & ឌីហ្សាញ** ថា ៖ ក្រោយពីការវាយតម្លៃលើឯកសារដាក់ដេញថ្លៃពីគ្រប់ក្រុមហ៊ុន ដែលបានបើកជាសាធារណៈកាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៧ ដើម្បីសាងសង់បន្ទប់បន្ថែមនិងដំបូលអគារនាយកដ្ឋានអាជីវកម្ម និងការជួសជុល កែសម្រួលបន្ទប់ដាក់ធុងក្ល័រ និងឃ្លាំងស្តុកអំបិលដែលស្ថិតនៅរោងចក្រផលិតទឹកស្អាតជ្រោយចង្វារ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានសម្រេចប្រគល់កិច្ចសន្យាជូនទៅក្រុមហ៊ុន **អេស២ អេនជីនារីង & ឌីហ្សាញ** ក្នុងតម្លៃកិច្ចសន្យាចំនួន **៤២៦,២២២,៧៥០រៀល (បួនរយម្ភៃប្រាំមួយលានពីររយម្ភៃពីរពាន់ប្រាំពីររយហាសិបរៀលគត់)**។

អាស្រ័យហេតុនេះ សូមលោកស្រីប្រធានពិនិត្យ និងចុះហត្ថលេខាលើកិច្ចសន្យា ដែលបានជូនភ្ជាប់ រួចប្រគល់មករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដោយមានភ្ជាប់មកជាមួយនូវប្រាក់កក់ធានាលើការអនុវត្តកិច្ចសន្យា (Performance Security) ដោយអនុលោមទៅតាមលក្ខខណ្ឌនៃកិច្ចសន្យា ក្នុងអំឡុងពេលមិនលើសពី១៥ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យានេះ។

សូមលោកស្រីប្រធានទទួលយកនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**ជ. គណៈកម្មាធិការលទ្ធកម្ម**

**អនុប្រធានទី១**

**បណ្ឌិត. ជា វិសុទ្ធ**

ចម្លងជូន៖

-ក្រុមហ៊ុន កៅ គីមសាន ហួលនីង

-ក្រុមហ៊ុន អេច យូ ឌី ស៊ី

-ក្រុមហ៊ុន ខ្មែរ ទំនើប ពាណិជ្ជ & សំណង់

អាសយដ្ឋានៈ លេខ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ទូរស័ព្ទៈ ៨៥៥(២៣) ៧២៤ ០៤៦ Email: admin@ppwsa.com.kh